១៦២៦ -	លោកគ្រូពេទ្យ	**យុ ឡេងថន**	ប្រធានការិយាល័យរដ្ឋបាល បុគ្គលិក ក្រុងកែប
១៦២៧ -	លោកវេជ្ជបណ្ឌិត	**លៀង តា**	អនុប្រធានការិយាល័យបច្ចេកទេស ក្រុងកែប
១៦២៨ -	លោក	**ប៉ែន អ៊ុនណារុន្ឋ**	ប្រធានការិយាល័យគណនេយ្យ ក្រុងកែប
១៦២៩ -	លោក	**លី ខេមរ៉ា**	អនុប្រធានការិយាល័យគណនេយ្យ ក្រុងកែប
១៦៣០ -	លោក	**គាត ហួង**	អនុប្រធានការិយាល័យរដ្ឋបាល បុគ្គលិក ក្រុងកែប
១៦៣១ -	លោក	**អ៊ុក សុវណ្ណារ៉ុង**	អនុប្រធានការិយាល័យឱសថ ក្រុងកែប
១៦៣២ -	លោកវេជ្ជបណ្ឌិត	**ជីវ ចំន្ទឌីណា**	អនុប្រធានមន្ទីរពេទ្យបង្អែកក្រុងកែប
១៦៣៣ -	លោក	**លឹម អាង**	ប្រធានមណ្ឌលសុខភាពពងទឹក ក្រុងកែប
១៦៣៤ -	លោកវេជ្ជបណ្ឌិត	**គីម សុខន**	អនុប្រធានមន្ទីរសុខាភិបាលក្រុងប៉ៃលិន
១៦៣៥ -	លោកវេជ្ជបណ្ឌិត	**លុយ សុភាព**	អនុប្រធានមន្ទីរសុខាភិបាលក្រុងប៉ៃលិន
១៦៣៦ -	លោកវេជ្ជបណ្ឌិត	**ឃិត សារឿម**	អនុប្រធានមន្ទីរសុខាភិបាលក្រុងប៉ៃលិន
១៦៣៧ -	លោកគ្រូពេទ្យ	**ប្រាក់ សារឿន**	អនុប្រធានមន្ទីរសុខាភិបាលខេត្តមណ្ឌលគិរី
១៦៣៨ -	លោកគ្រូពេទ្យ	**ពុយ ពិសី**	អនុប្រធានមន្ទីរសុខាភិបាលខេត្តមណ្ឌលគិរី
១៦៣៩ -	លោកវេជ្ជបណ្ឌិត	**ប៉ែន សុណា**	អនុប្រធានមន្ទីរសុខាភិបាលខេត្តស្វាយរៀង
១៦៤០ -	លោកវេជ្ជបណ្ឌិត	**វន វិណារ៉ា**	អនុប្រធានមន្ទីរសុខាភិបាលខេត្តស្វាយរៀង

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ....៥៧៨...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ជូនអ្នកជំនាញការសហភាពអឺរ៉ុប ចំនួន ០៩ រូប និង មន្ត្រីកម្ពុជាជាដៃគូ ចំនួន ០៧ រូប ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត ក្នុងការអនុវត្ត គំរោងកម្មវិធីស្តារ និង ទ្រទ្រង់វិស័យកសិកម្ម នៅកម្ពុជា (**PRASAC**) ដែលមានទឹកប្រាក់ជំនួយសរុបចំនួន ៧៨.៨ លាន **EURO** ដូចមានរាយនាមខាងក្រោម ÷

ក- មេដាយមាសស្ថាបនាជាតិ :

១- លោក **Manfred Staab**	សហនាយកប្រាសាក់ ២
២- លោក **ឡៅ នី**	សហនាយកប្រាសាក់ ២
៣- លោក **Martin Wolf**	ជំនាញការផ្នែក **Rural Development**
៤- លោក **Karl Heinz Ochs**	ជំនាញការផ្នែក **Rural Engineer**
៥- លោក **Degenhardt Joachim**	ជំនាញការផ្នែកភស្តុភា
៦- លោក **Michael Krieger**	សហប្រធានប្រាសាក់ ២ កំពង់ចាម
៧- លោក **គួន មិន**	សហប្រធានប្រាសាក់ ២ កំពង់ចាម
៨- លោក **Raubold Wulf**	សហប្រធានប្រាសាក់ ២ កំពង់ស្ពឺ
៩- លោក **ជួប សែ**	សហប្រធានប្រាសាក់ ២ កំពង់ស្ពឺ
១០- លោក **ប៉ុញ សទ្ធះ**	សហប្រធានប្រាសាក់ ២ កំពង់ឆ្នាំង
១១- លោក **ស៊ឹ សាហាក់**	សហប្រធានប្រាសាក់ ២ ស្វាយរៀង
១២- លោក **ស៊ុន ឌៃហេង**	អ្នកសំរបសំរួលផ្នែកភស្តុភា
១៣- អ្នកស្រី **អ៊ិុន ដាវី**	លេខាសហនាយកប្រាសាក់ ២

ខ. មេដាយស្ថាបនាជាតិ :

១- លោក **Wolfram Jaeckel** ជំនាញការផ្នែក **MIS / M & E / GIS**

២- លោក **Johann Friedrich Ramm** ជំនាញការផ្នែក **Credit**

៣- លោក **Eberhard Goehsing** សហប្រធានប្រាសាទ ២ កំពង់ឆ្នាំង

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៤៧៩...អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម **ហ៊ី ធារី** អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ ដែលបានបរិច្ចាគថវិកាចំនួន ២១.២៥៨ USD ជួយកសាងក្លោងទ្វារ និង ផ្លូវចាក់បេតុង ចូលទៅវត្តភ្នំប្រសិទ្ធិត្រ័យត្រឹង្ស ស្ថិតនៅក្នុងឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល ។

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៣០ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការផ្ទេរភារកិច្ចនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា១ : ត្រូវបានផ្ទេរភារកិច្ចនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃដូចមានរាយនាមខាងក្រោម:

១- លោកឧត្តមសេនីយ៍ត្រី **ពេជ្រ ជីម៉ន** អត្តលេខ ០១០២ ពីប្រធានមន្ទីរប្រឆាំងគ្រឿងញៀន ទៅជាទីប្រឹក្សាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

២- លោកឧត្តមសេនីយ៍ត្រី **ខាំង ណយ** អត្តលេខ០២០៣ ពីទីប្រឹក្សាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទៅជាប្រធានមន្ទីរប្រឆាំងគ្រឿងញៀន ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry , Mines and Energy
N° ៧១១ ឧរថ ឧកស.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៧៩០ ឧក.ប្រក ចុះថ្ងៃទី ១៧-៨-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ របស់លោក ជា ហឿង ចុះថ្ងៃទី ១៥-៨-០២ ។

សំរេច

ប្រការ១:- អនុញ្ញាតអោយលោក ជា ហឿង ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩១២៦៨ព.ស ចុះថ្ងៃទី ២៥-៦-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៨ ភូមិពាលញែក១ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិសាត់ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង១២០សេះ នៅក្នុងទីតាំង ភូមិស្វាយអាត់ ឃុំស្វាយអាត់ ស្រុកសំពៅមាស ខេត្តពោធិសាត់ ។

ប្រការ២:- លោក ជា ហឿង ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ៣:- ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ៤:- អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តពោធិសាត់ និង លោក ជា ហឿង ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ៥:- ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្ត ពោធិសាត់
-សាលាស្រុក សំពៅមាស
"ដើម្បីជ្រាប"
-ដូចប្រការ ៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

សែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry , Mines and Energy
N°៧១២ ឧរថ.ឧស-ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៧៩១ ផក.ប្រក ចុះថ្ងៃទី ១៧-៨-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ របស់លោក នូ **គីមស៊ាន** ចុះថ្ងៃទី ១៥-៨-០២ ។

សំរេច

ប្រការ១:- អនុញ្ញាតអោយលោក នូ **គីមស៊ាន** ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០០០៩៦៣ព.ស ចុះថ្ងៃទ ០៨-៥-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៩ ភូមិពាលញែក១ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិសាត់ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង១២០សេះ នៅក្នុងទីតាំង ក្រុមទី២ ភូមិអូរស្តៅ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិសាត់ ។

ប្រការ២:- លោក នូ **គីមស៊ាន** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ៣:- ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ៤:- អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តពោធិសាត់ និង លោក នូ **គីមស៊ាន** ត្រូវទទួលបេអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ៥:- ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្ត ពោធិសាត់
-សាលាស្រុក សំពៅមាស
"ដើម្បីជ្រាប"
-ដូចប្រការ ៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ស៊ុយ សែម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry , Mines and Energy

N°៧១៣ ឧរថ្ម/តល-ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២

<u>ប្រកាស</u>

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៨១៣ ឧក.ប្រក ចុះថ្ងៃទី ១៩-៨-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ របស់លោក **ឈរ ហុងលី** ចុះថ្ងៃទី ១៥-៨-០២ ។

<u>សំរេច</u>

<u>ប្រការ១:</u>~ អនុញ្ញាតអោយលោក **ឈរ ហុងលី** ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ១១៦៤១៣ព.ស ចុះថ្ងៃទី ២១-១០-៩០ អាស័យដ្ឋានបច្ចុប្បន្ន ភូមិត្នោតទ្រេត ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិសាត់ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

<u>ប្រការ២:</u>~ លោក **ឈរ ហុងលី** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

<u>ប្រការ៣:</u>~ ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

<u>ប្រការ៤:</u>~ អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តពោធិសាត់ និង លោក **ឈរ ហុងលី** ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

<u>ប្រការ៥:</u>~ ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ចំលងជូន:</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្ត ពោធិសាត់
- សាលាស្រុក សំពៅមាស "ដើម្បីជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ស៊ុយ_សែម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry , Mines and Energy

N°៧១៤ ឧរថ ឧសល - ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៧៨៤ ឧក.ប្រក ចុះថ្ងៃទី ១៧-៨-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ របស់លោក **លី ទ្រី** ចុះថ្ងៃទី ០៧-៧-០២ ។

សម្រេច

ប្រការ១:~ អនុញ្ញាតអោយលោក **លី ទ្រី** ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៨៥៧៥៨ ក.ច ចុះថ្ងៃទី ១៤-៦-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិល្អុង ឃុំរលេច ស្រុកបាកាន ខេត្តពោធិសាត់ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង១២០សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ២:~ លោក **លី ទ្រី** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានាឆ្លូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ៣:~ ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ៤:~ អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តពោធិសាត់ និង លោក **លី ទ្រី** ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ៥:~ ប្រកាសនេះមានអនុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ សែម

ចំលងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្ត ពោធិសាត់
-សាលាស្រុក បាកាន
"ដើម្បីជ្រាប"
-ដូចប្រការ ៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry . Mines and Energy

N° ៧១៥ ... ឧស.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៧៩២ ផក.ប្រក ចុះថ្ងៃទី ១៧-៨-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ របស់លោក ស៊ែ ឃន់ ចុះថ្ងៃទី ១៥-៨-០២ ។

សំរេច

ប្រការ១:~ អនុញ្ញាតអោយលោក ស៊ែ ឃន់ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨៦៧៩៩ ក.ច ចុះថ្ងៃទី ១៤-៥-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៩ ភូមិត្នោតទ្រេត ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិសាត់ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង១២០សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ២:~ លោក ស៊ែ ឃន់ ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ៣:~ ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ៤:~ អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តពោធិសាត់ និង លោក ស៊ែ ឃន់ ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ៥:~ ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ 1: Vue

ចំលងជូន:
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -រាជកិច្ច
- -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -សាលាខេត្ត ពោធិសាត់
- -សាលាស្រុក សំពៅមាស
  "ដើម្បីជ្រាប"
- -ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ស៊ុយ សែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry , Mines and Energy
N° ៧៦៦ ឧរថ ឧគស.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៧៧៨ ឧក.ប្រក ចុះថ្ងៃទី ១៧-៨-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម របស់លោក ហេង ផុន ចុះថ្ងៃទី ២៤-៨-០២ ។

សម្រេច

ប្រការ១: អនុញ្ញាតអោយលោក **ហេង ផុន** ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០០១៣៧៥ ព.ស ចុះថ្ងៃទី ២៦-៩-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី២ ភូមិពោះពួយ ឃុំលាច ស្រុកភ្នំក្រវាញ ខេត្តពោធិសាត់ បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ២: ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រការ៣: អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តពោធិសាត់ និង លោក **ហេង ផុន** ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ៤: ប្រកាសនេះមានអនុភាពអនុវត្តន៍ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្ត ពោធិសាត់
-សាលាស្រុក ភ្នំក្រវាញ
"ដើម្បីជ្រាប"
-ដូចប្រការ ៣ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ស៊ុយ សែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry . Mines and Energy
N°៧១៧ ឧរម.ឧសព-ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ. នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៨០២ ផក.ប្រក ចុះថ្ងៃទី ១៩-៨-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម របស់លោក ស្វៀង ហ៊ួរ ចុះថ្ងៃទី ១៧-៨-០២ ។

សំរេច

ប្រការ១:- អនុញ្ញាតអោយលោក ស្វៀង ហ៊ួរ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦៩៨០៨ព.ស ចុះថ្ងៃទី ៣០-១១-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៣ ភូមិបឹងខ្នារ ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិសាត់ បន្តដំណើរការឧស្សាហកម្មតូចផលិត ទឹកកកដើម នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ២:- ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រការ៣:- អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តពោធិសាត់ និង លោក ស្វៀង ហ៊ួរ ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ៤:- ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្ត ពោធិសាត់
-សាលាស្រុក បាកាន
"ដើម្បីជ្រាប"
-ដូចប្រការ ៣ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ •

ស៊ុយ សែម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry , Mines and Energy

N°៧១៨ ឧរថ ឧកសរ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ របស់លោក **លីម ម៉េង** ចុះថ្ងៃទី ២៩-៨-០២ ។
- បានឃើញការយល់ព្រមលេខ ២០៩៥ ខបជ. ចុះថ្ងៃទី ០៩-១០-០២ របស់អភិបាលខេត្តបន្ទាយមានជ័យ ។

សំរេច

ប្រការ១: អនុញ្ញាតអោយលោក **លីម ម៉េង** កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១៩០០៣៦៦៣២ ចុះថ្ងៃទី ០៦-៦-០១ អាសយដ្ឋានបច្ចុប្បន្ន ភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៧១សេះ នៅក្នុងទីតាំង ក្រុមទី១ ភូមិព្រៃកជីក ឃុំបត់ត្រង់ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

ប្រការ២: លោក **លីម ម៉េង** ត្រូវបើកដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ៣: ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ៤: អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តបន្ទាយមានជ័យ និង លោក **លីម ម៉េង** ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្ត បន្ទាយមានជ័យ
- សាលាស្រុក មង្គលបូរី
  "ដើម្បីជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ស៊ុយ សែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry , Mines and Energy

N° ៧១៩ ឧ.ម.ឧ.ស.-ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ របស់លោក ហ៊ិន សេង ចុះថ្ងៃទី ១០-៤-០២ ។
- បានឃើញការយល់ព្រមលេខ ១២៤៤ ខពស. ចុះថ្ងៃទី ២៩-៧-០២ របស់អភិបាលខេត្តពោធិសាត់ ។

សំរេច

ប្រការ១:~ អនុញ្ញាតអោយលោក **ហ៊ិន សេង** កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១៦០០១៦៤៧៥ ចុះថ្ងៃទី ០៧-៥-០១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិអូរតូង ឃុំចំរើនផល ស្រុកសំពៅមាស ខេត្តពោធិសាត់ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២០សេះ នៅក្នុងទីតាំង ភូមិស្តុកស្វាយ ឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិសាត់ ។

ប្រការ២:~ លោក **ហ៊ិន សេង** ត្រូវបើកដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ៣:~ ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ៤:~ អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តពោធិសាត់ និង លោក **ហ៊ិន សេង** ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ៥:~ ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្ត ពោធិសាត់
- សាលាស្រុក បាកាន
  "ដើម្បីជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ស៊ុយ សែម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry , Mines and Energy

N° ៧៧០ ឧរថ.ឧកស.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម ធ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម ធ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បើកដំណើរការឡផលិតឥដ្ឋគ្រប់ប្រភេទ របស់អ្នកស្រី **សារី ផន** ចុះថ្ងៃទី ១៩-៦-០២ ។
- បានឃើញការយល់ព្រមលេខ ១០៩០ ខកក. ចុះថ្ងៃទី ១៩-៨-០២ របស់អភិបាលខេត្តកោះកុង ។

សំរេច

ប្រការ១:~ អនុញ្ញាតអោយអ្នកស្រី **សារី ផន** កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១៥០០០០៥០៨ ចុះថ្ងៃទី ២១-១២-០១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ១ ឃុំដងទង់ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង បើកដំណើរការឡផលិតឥដ្ឋគ្រប់ប្រភេទ នៅក្នុងទីតាំងផ្ទះគ្មានលេខ ភូមិកោះប៉ោ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ។

ប្រការ២:~ ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ៣:~ អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម ធ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម ធ៉ែ និង ថាមពល ខេត្តកោះកុង និង អ្នកស្រី **សារី ផន** ត្រូវទទួលអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ៤:~ ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្ត កោះកុង
- សាលាស្រុក មណ្ឌលសីមា

"ដើម្បីជ្រាប"

- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

...សែម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ ១២៩៤ សកបយ

ភ្នំពេញ.ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

ស្តីពី

ការបង្កើតអង្គភាពពលករបរទេស

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញ លិខិតលេខ ១ ១៦៦ សជណ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : បង្កើត **អង្គភាពពលករបរទេស** ជាភាសាអង់គ្លេសហៅថា FOREIGN WORKER UNIT ស្ថិតនៅក្នុងអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីគ្រប់គ្រងពលករបរទេសទាំងអស់ នៅក្នុងព្រះរាជាណាចក្រ៕

កម្ពុជា ដែលស្ថិតនៅក្រោមបទបញ្ញត្តិ នៃច្បាប់ស្តីពីការងារ ។

ប្រការ ២: **អង្គភាពពលករបរទេស** ជាអង្គភាពអន្តរនាយកដ្ឋានពាក់ព័ន្ធ មានតួនាទីសម្របសម្រួល និងផ្តល់សេវាកម្ម ចំពោះសហគ្រាសគ្រឹះស្ថាននានា ដែលប្រើប្រាស់ជនបរទេស និងជួយបង្កើនប្រសិទ្ធិភាព នៃការគ្រប់គ្រងពលករបរទេស របស់នាយកដ្ឋានមុខរបរនិងហត្ថពលកម្ម នាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ និងនាយកដ្ឋានពេទ្យការងារ ។

អង្គភាពពលករបរទេស មានភារកិច្ច ដូចតទៅ :

១-ផ្តល់សេវាក្នុងការងារគុំកូតា ការស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស រៀបចំកិច្ចសន្យាការងាររវាងជនបរទេសនិងនិយោជក រៀបចំបែបបទសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកចេញ និងចូល ។

២-ផ្តល់សេវានៃការស្នើសុំធ្វើប័ណ្ណការងារ និងសៀវភៅការងារថ្មីនៃជនបរទេស និងពន្យាសុពលភាពនៃប័ណ្ណ និងសៀវភៅ ។ ទទួលអាករប័ណ្ណការងារ និងសៀវភៅការងារ និងបង់ ចូលថវិការដ្ឋ តាមការកំណត់របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

៣-សហការជាមួយក្រសួងមហាផ្ទៃ តំណាងការងារទូតប្រទេសដើមរបស់ពលករបរទេស និងសមាគមនិយោជក និងនិយោជក ដើម្បីដោះស្រាយរាល់ការងារដែលពាក់ព័ន្ធជាមួយជនបរទេស ។

៤-គ្រប់គ្រងការងារអធិការកិច្ចហត្ថពលកម្មបរទេស និងទំនាក់ទំនងវិជ្ជាជីវៈរវាងពលករបរទេស និងនិយោជក ។

ប្រការ ៣ : បង្កើតលេខាធិការដ្ឋានមួយនៅក្នុងនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ជាជំនួយការរបស់ **អង្គភាពពលករបរទេស** ដែលមានមន្ត្រីជំនាញបំរើការមកពីនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នាយកដ្ឋានពេទ្យការងារ និងនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ ។

សមាសភាពមន្ត្រីនៃលេខាធិការដ្ឋានរួមមាន:

១-លោក ហ៊ូ វុទ្ធី	អគ្គនាយករងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	ប្រធាន
២-លោក សេង សក្តា	ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម	អនុប្រធាន
៣-លោក ឃួន ឡានិច	អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម	សមាជិក
៤-លោក ស្រេង ជូឡុង	ប្រធានការិយាល័យស្ថិតិមុខរបរ និងហត្ថពលកម្ម	សមាជិក
៥- លោក ឆាំង ហាក់យូ	អនុប្រធានការិយាល័យត្រួតពិនិត្យជនបរទេស	សមាជិក
៦-លោក អ៊ឹង វ័ត្តធីណា	អនុប្រធានការិយាល័យត្រួតពិនិត្យជនបរទេស	សមាជិក
៧-លោក ឃុន ពិសិដ្ឋា	មន្ត្រីការិយាល័យត្រួតពិនិត្យជនបរទេស	សមាជិក
៨-លោក ជូរ រតនៈ	មន្ត្រី នាយកដ្ឋានពេទ្យការងារ	សមាជិក

៩-លោក ជួន ឃុន មន្ត្រីនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈនិងទីផ្សារការងារ សមាជិក

មន្ត្រី ដែលត្រូវបានចាត់តាំងឱ្យទទួលភារកិច្ច នៅក្នុងលេខាធិការដ្ឋាននៃ **អង្គភាពពលករបរទេស** ត្រូវបានរក្សាក្របខ័ណ្ឌ បៀវត្ស ការដំឡើងឋានៈ និងការលើកសរសើរនៅអង្គភាពដើម ។

ប្រការ ៤: អង្គភាពពលករបរទេស ត្រូវសហការឱ្យបានល្អជាមួយ នាយកដ្ឋានជនបរទេស នៃអគ្គនាយកដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ក្នុងដំណើរការអនុវត្តន៍ភារកិច្ចដែលពាក់ព័ន្ធ ។

ប្រការ ៥: ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ និង នាយកដ្ឋានពេទ្យការងារ និង មន្ត្រីដែលទទួលភារកិច្ច នៅក្នុងប្រការ៣ ត្រូវអនុវត្តប្រកាសនេះប្រកបដោយប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

<u>ចម្លងជូន</u> :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-សមាគមនិយោជក នៃព្រះរាជាណាចក្រកម្ពុជា

" <u>ដើម្បីជូនជ្រាប</u> "

-ដូចប្រការ ៣ និងប្រការ ៥

" <u>ដើម្បីអនុវត្ត</u> "

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៧៩៧ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ ស្រែរនោង

ស្ថិតនៅក្នុងឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០៧ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចនមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំស្រែរនោង ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ ដោយមានយោបល់ឯកភាពពី មន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

សម្រេច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា: អនុវិទ្យាល័យ « ស្រែរនោង »ស្ថិតនៅក្នុងឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកអនុវិទ្យាល័យសាមីមាន ភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០២

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តតាកែវ " ដើម្បីជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ ន.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៧៩៤ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន ត្រសេកកោង ស្ថិតនៅក្នុងឃុំថ្មី ស្រុកកំពត ខេត្តកំពត

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំថ្មី ស្រុកកំពត ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ដោយមានយោបល់ឯកភាពពីមន្ទីរ អប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពត
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ហ៊ុន សែន ត្រសេកកោង » ស្ថិតនៅក្នុងឃុំថ្មី ស្រុកកំពត ខេត្តកំពត ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ច រៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តកំពត " ដើម្បីជាពត៌មាន "
- ដូចប្រការ ៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ...៧៥៩...អយក.ប្រក

ប្រកាស

ស្តីពីការបើក អនុវិទ្យាល័យ « សំណាប » ស្ថិតក្នុងឃុំព្រៀងញាំង ស្រុកត្រាំកក់ ខេត្តតាកែវ ។

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា។
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចរមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២។
- យោងលិខិតស្នើសុំរបស់ មន្ទីរអប់រំ យុវជន និង កីឡាខេត្តតាកែវ លេខ ៣៤១០ អយក.បចម ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០២ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តតាកែវ ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា:អនុវិទ្យាល័យ « សំណាប » ស្ថិតនៅក្នុងឃុំព្រៀងញាំង ស្រុកត្រាំកក់ ខេត្តតាកែវ ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២

ស.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

អ៊ឹម_សិទ្ធី

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តតាកែវ " ដើម្បីជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៩០០ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ សន្លុង

ស្ថិតនៅក្នុងឃុំសន្លុង ស្រុកទ្រាំង ខេត្តតាកែវ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំសន្លុង ស្រុកទ្រាំង ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០២ ដោយមានយោបល់ឯកភាព ពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

សំ រេ ច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « សន្លុង » ស្ថិតនៅក្នុងឃុំសន្លុង ស្រុកទ្រាំង ខេត្តតាកែវ ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអត្តការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកអនុវិទ្យាល័យសាមីមាន ភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ២០០២

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

អ៊ឹម_សិទ្ធី

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តតាកែវ " ដើម្បីជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ ន.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៤០៦ អយក.ប្រក

ប្រកាស

ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ

« អូរប្រាសាទ » ទៅជាវិទ្យាល័យ « ភ្នំធំ »

ស្ថិតនៅក្នុងឃុំអូរប្រាសាទ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំអូរប្រាសាទ ស្រុកមង្គលបុរី ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និង អភិបាលខេត្តបន្ទាយមានជ័យ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

សម្រេច

ប្រការ ១ : អនុញ្ញាតអោយពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ «អូរប្រាសាទ» បច្ចុប្បន្ន ទៅជាវិទ្យាល័យ « ភ្នំធំ » ស្ថិតនៅក្នុងឃុំអូរប្រាសាទ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំយុវជននិងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ និងនាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០០២

ស.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

__កន្លែងទទួល__
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្តបន្ទាយមានជ័យ "ដើម្បីជាពត៌មាន"
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ នា.មបទ

C:\New school\Increase 2.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ...៥០២......អយក.ប្រក

ប្រ កា ស

ស្តីពីការពង្រីកអនុវិទ្យាល័យ « ជប់វារី »

ទៅជាវិទ្យាល័យ « ជប់វារី » ស្ថិតនៅក្នុងឃុំជប់វារី

ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា។
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និង កីឡា ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២។
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០២ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តបន្ទាយមានជ័យ ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ។

ស ម្រេ ច

ប្រការ ១ : អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ « ជប់វារី » បច្ចុប្បន្ន ទៅជាវិទ្យាល័យ « ជប់វារី » ស្ថិតនៅឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ។

ប្រការ ៣ : នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំយុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ និងនាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០០២

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តបន្ទាយមានជ័យ " ដើម្បីជាពត៌មាន "
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ ឆា.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៤០៣ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ ភ្នំលក

ស្ថិតនៅក្នុងឃុំប្ញស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់ការិយាល័យអប់រំស្រុកកំពង់ត្រាច លេខ ២២៧ អយក.សកត ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពត
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ភ្នំលក » ស្ថិតនៅក្នុងឃុំប្ញស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០២

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តកំពត " ដើម្បីជាពត៌មាន "
- ដូចប្រការ ៤

កាលប្បវត្តិ ឯកសារ ខ.មចទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ : ១៧១/ប្រក ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ១១ ឆ្នាំ២០០២

ប្រកាស

ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគំរោង (PMU) និងតែងតាំងនាយក និង អ្នកគ្រប់គ្រង សំរាប់អនុវត្តគំរោង ក្នុងក្របខ័ណ្ឌឥណទាននៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការបង្កើតរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើនូវច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញសេចក្តីសំរេចលេខ ១៧៩១ សសរ/អជប ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការ បែងចែក ភារកិច្ច និង ការកំណត់របៀបរបបធ្វើការរបស់ថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ
- អនុស្សារណៈយោគយល់គ្នា របស់ ADB's Mission ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០២
- យោងតាមតំរូវការចាំបាច់

សំរេច

ប្រការ១: ត្រូវបានបង្កើតឡើងនូវអង្គភាពគ្រប់គ្រងគំរោង (PMU) សំរាប់អនុវត្តគំរោងឥណទាន នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានស្នាក់ការនៅនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ ។

ប្រការ២: តែងតាំង នាយកគំរោង (Project Director) និង អ្នកគ្រប់គ្រងគំរោង (Project Manager) សំរាប់អនុវត្តគំរោងផ្គត់ផ្គង់ទឹកជនបទ និង អនាម័យ ក្នុងខេត្តកំពង់ធំ ខេត្តកំពត និង ខេត្តពោធិសាត់ ក្នុងក្របខ័ណ្ឌឥណទាន នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានសមាសភាពដូចខាងក្រោម:

១- ឯកឧត្តម **ជី សុវណ្ណា** នាយកគំរោង

២- លោក **នួន តេជ្ជនិមិត្ត** អ្នកគ្រប់គ្រងគំរោង

ប្រការ៣: មន្ត្រីដូចមានចែងក្នុងប្រការ២ មានភារកិច្ចទទួលខុសត្រូវក្នុងការដឹកនាំអនុវត្តគំរោង ក្នុងក្របខ័ណ្ឌឥណទាន នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដូចមានចែងក្នុងឯកសារគំរោង ។

ប្រការ៤: អគ្គនាយកទាំងពីរ អគ្គាធិការ ខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ ខេត្តកំពត និង ខេត្តពោធិសាត់ និង សាមីជនដូចមានចែងក្នុងប្រការ២ មានភារកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

លី-ធុជ

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ កំពត និង ពោធិសាត់
- ធនាគារអភិវឌ្ឍន៍អាស៊ី ADB

ដើម្បីជូនជ្រាប:

- ដូចមានចែងក្នុងប្រការ ៤

ដើម្បីអនុវត្ត:

- ឯកសារ-កាលប្បវត្តិ